**FOR IMMEDIATE RELEASE**

USAID Supporting Forests and Biodiversity Project
Phnom Penh Center, Building F, Room 588, Sothearos Blvd
Phone/Fax: +855 (0)23 220 714, E-mail: infosfb@winrock.org

# PRESS RELEASE

# សៀវភៅកម្រងសត្វព្រៃក្នុងដែនជម្រកសត្វព្រៃភ្នំព្រេចក្នុងខេត្តមណ្ឌលគិរី បង្ហាញពីរតនសម្បត្តិរបស់ប្រទេសកម្ពុជា ដាក់អោយប្រើប្រាស់ជាផ្លូវការក្នុងថ្ងៃនេះ

**ភ្នំពេញ ថ្ងៃទី២១ កក្កដា ២០១៦-** តាមរយៈគម្រោងគាំទ្រព្រៃឈើនិងជីវចម្រុះរបស់ទីភ្នាក់ងារសហរដ្ឋអាមេរិកសំរាប់ការអភិវឌ្ឍន៍អន្តរជាតិ **(USAID)** ដែលអនុវត្តដោយអង្គការ Winrock អន្តរជាតិ និង WWF-កម្ពុជា រួមសហការជាមួយ និងក្រសួងបរិស្ថានបានធ្វើការសម្ពោធចែកចាយនូវសៀវភៅកម្រងសត្វព្រៃក្នុងដែនជម្រកសត្វព្រៃភ្នំព្រេចក្នុងខេត្តមណ្ឌលគីរី នៅថ្ងៃនេះដែលរៀបចំឡើងនៅក្រសួងបរិស្ថាន។ សៀវភៅនេះមាន៧៦ទំព័រ បង្ហាញនូវប្រភេទសត្វសំខាន់ៗបំផុត រួមជាមួយ និងរូបភាពដ៏ស្រស់ស្អាតរបស់សត្វទាំងនោះ និងពិពណ៌នាពីការងារអភិរក្សនៅក្នុងដែនជំរកសត្វព្រៃភ្នំព្រេច។

លោក ឈិត សំអាត នាយកអង្គការ WWF-កម្ពុជា មានប្រសាសន៍ថា៖ "តាមរយៈសៀវភៅនេះ យើងចង់បង្កើនការយល់ដឹងពីសារៈសំខាន់នៃជីវចម្រុះដែលមាននៅក្នុងតំបន់ដែនជម្រកសត្វព្រៃភ្នំព្រេចដល់ប្រជាពលរដ្ឋកម្ពុជា ជាពិសេសគឺយុវជន យុវនារី និងសិស្សានុសិស្សដើម្បីអោយពួកគាត់យល់ដឹងពីមរតកដ៏មានតំលៃរបស់ប្រទេសកម្ពុជាយើង និងចូលរួមចំណែកក្នុងការអភិរក្សទាំងអស់គ្នា។"

ដែនជម្រកសត្វព្រៃភ្នំព្រេច គឺជាទីជម្រកសត្វព្រៃជាច្រើនប្រភេទរួមទាំងសត្វដែលរងគ្រោះជិតផុតពូជចំនួន១៨ប្រភេទផងដែរ។ វាមិនត្រឹមតែជាជម្រកសត្វទាំងនោះប៉ុណ្ណោះទេ តែវាក៏ផ្តល់នូវគុណតំលៃផ្នែកសង្គម សេដ្ឋកិច្ច និងវប្បធម៌ផងដែរដល់ប្រជាសហគមន៍ដែលរស់នៅទីនោះ។ ប្រជាសហគមន៍ទាំងនោះគឺពឹងផ្អែកទៅលើធនធានធម្មជាតិដែលមាននៅក្នុងព្រៃនេះក្នុងការចិញ្ចឹមជីវិតរបស់ពួកគាត់។

ព្រៃឈើ និងសត្វព្រៃនៅក្នុងដែនជម្រកសត្វព្រៃភ្នំព្រេច កំពុងទទួលរងនូវការគំរាមកំហែងពីការបាត់បង់នូវទីជម្រក ការបរបាញ់ និងការកាប់បំផ្លាញព្រៃឈើខុសច្បាប់ជាដើម។ គម្រោងគាំទ្រព្រៃឈើ និងជីវចម្រុះរបស់ទីភ្នាក់ងារសហរដ្ឋអាមេរិកសំរាប់ការអភិវឌ្ឍន៍អន្តរជាតិ (USAID) បានកំពុងតែនឹងសហការជាមួយក្រសួងបរិស្ថាន អគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ (GDANCP) ដើម្បីធ្វើការការពារ និងអភិរក្សតំបន់នេះ។

ឯកឧត្តមបណ្ឌិត សាយ សំអាល់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន មានប្រសាសន៍ថា៖ "យើងធ្វើការគាំទ្រនូវកិច្ចការរបស់ USAID អង្គការ WWF-កម្ពុជា អង្គការ Winrock អន្តរជាតិ និងនាយកដ្ឋានពាក់ព័ន្ធរបស់ក្រសួងបរិស្ថានទាំងអស់ដែលខិតខំប្រឹងប្រែងធ្វើការជាមួយគ្នាក្នុងការផលិតនូវសមិទ្ធិផលដ៏ល្អមួយនេះ។ យើង

សង្ឃឹមថាសៀវភៅមួយក្បាលនេះអាចជួយលើកកម្ពស់ដល់ការយល់ដឹងអំពីសក្តានុពលរបស់ដែនជម្រក និងសារៈសំខាន់របស់វាសំរាប់ពិភពលោកទាំងមូល។”

ដែនជម្រកសត្វព្រៃភ្នំព្រេចលាតសន្ធឹងនៅចន្លោះដែនជម្រកសត្វព្រៃស្រែពក និងដែនជម្រកសត្វព្រៃកែវសីម៉ា ហើយដែលមានផ្ទៃដីប្រមាណជាង ២,០០០គីឡូម៉ែតការ៉េ ដែលស្ថិតនៅចំកណ្តាលតំបន់ទេសភាពខ្ពង់រាបភាគខាងកើតនៃប្រទេសកម្ពុជា។ តំបន់ទេសភាពខ្ពង់រាបភាគខាងកើត គឺជាតំបន់ការពារដ៏ធំធេងមួយ និងត្រូវបានចាត់ទុកថាជាតំបន់ដែលមានសារៈសំខាន់ជាអន្តរជាតិសំរាប់ប្រភេទសត្វរុក្ខជាតិដែលរងគ្រោះជិតផុតពូជរបស់ពិភពលោក។

ការសម្ពោធចែកចាយជាផ្លូវការនូវសៀវភៅនេះរៀបចំធ្វើឡើងដោយអង្គការមូលនិធិសកលសំរាប់អភិរក្សធនធានធម្មជាតិ (WWF- កម្ពុជា) សហការជាមួយក្រសួងបរិស្ថាន អគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ (GDANCP) និងគាំទ្រជាថវិកាពីគម្រោងគាំទ្រព្រៃឈើ និងជីវចម្រុះរបស់ទីភ្នាក់ងារសហរដ្ឋអាមេរិកសំរាប់ការអភិវឌ្ឍន៍អន្តរជាតិ (USAID) ។

###


**សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនងៈ**

លោក អ៊ុន ចក្រី ប្រធានផ្នែកទំនាក់ទំនងរបស់អង្គការ WWF-កម្ពុជា

ទូរស័ព្ទ : +855 (0)17 234 555